# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ: ៩៩៧៦ អគ៣.អក.២អ៨

ថ្ងៃ សុក្រ ០៨ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា៖ គោលនយោបាយវិស័យថាមពលរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៦ នៃរដ្ឋសភានេះ **រាជរដ្ឋាភិបាលកម្ពុជា** មានមហិច្ឆតាគ្រប់គ្រង និងជំរុញការអភិវឌ្ឍវិស័យថាមពលអគ្គិសនីដើម្បី "ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែង ទូទាំងព្រះរាជាណាចក្រកម្ពុជា"។ **អគ្គិសនីកម្ពុជា** បន្តផ្តល់ថវិកាជាអំណោយដល់នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (ហៅកាត់ថា "ម.អ.ជ.") ដើម្បីបន្តអនុវត្ត "**កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ**"។ កម្មវិធីនេះជាកម្មវិធីអនុវត្តពីឆ្នាំ២០១៣ និងបន្តអនុវត្តក្នុងឆ្នាំ២០២១។ គោលបំណងនៃកម្មវិធី គឺជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាលដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាច ទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។ កម្មវិធីនេះបានជួយដល់គ្រួសារជនបទ ទទួលបាននូវផលប្រយោជន៍ច្រើន ដោយ ម.អ.ជ. បានផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកដល់គ្រួសារជនបទ ដែលបានទិញប្រព័ន្ធយកទៅប្រើប្រាស់ ហើយអ្នកទិញត្រូវបានអនុគ្រោះឲ្យសងរំលស់ថ្លៃនៅសល់ពីការឧបត្ថម្ភធនមក ម.អ.ជ. វិញ ក្នុងរយៈពេល ៤ឆ្នាំ។ ការផ្តល់ការអនុគ្រោះនេះមានគោលបំណងជួយគ្រួសារជនបទឲ្យទទួលបានអគ្គិសនីប្រើប្រាស់ ពីការផ្គត់ផ្គង់ថាមពលមួយប្រកបដោយសុវត្ថិភាព និងបង្កើនជីវភាពរស់នៅឲ្យប្រសើរឡើង ព្រមទាំងទទួលបាននូវថ្លៃអគ្គិសនីថោកជាង បើប្រៀបធៀបជាមួយការប្រើចង្កៀងប្រេងកាត ចង្កៀងម៉ាស៊ូត និងអាគុយជាដើម។ ម.អ.ជ. នឹងតម្លើងប្រព័ន្ធនេះជូនដល់ផ្ទះអ្នកទិញ។ ក្រោយពេលសងគ្រប់ចំនួន ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 015 776-770 / 011 244-246 ឬលោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 089 776-770 / 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅ ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

ចម្លងជូន៖
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ